**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦៧,៧៩៥២ ហិកតា នៅស្រុកឈូក ខេត្តកំពត ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន First Bio-Tech Agricultural ( Cambodia ) Co,.Ltd និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣១៧ ល.ស ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ **៦៧,៧៩៥២ ហិកតា** ក្នុងនោះ (១) ទំហំ **២៧,៤២៤៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និង (២) ទំហំ **៤០,៣៧០៩ ហិកតា** កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន First Bio-Tech Agricultural (Cambodia) Co,.Ltd និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មដីទំហំ **៦២.០៩៨២ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន **៨២ គ្រួសារ** និងដីទំហំ **៥,៦៩៧០ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតេជោជ្រៃបាក់ **ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត** តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតេជោជ្រៃបាក់ ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត ។



www.pheakdeylaw.com

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ ... នៃអនុក្រឹត្យលេខ...២៦ អនក្រ.បក.......... ចុះថ្ងៃទី១៧... ខែ មករា..... ឆ្នាំ២០១៤ ស្តីពីការកាត់ដីទំហំ ៦៧,៧៩៥២ហិកតា
នៅស្រុកឈូក ខេត្តកំពត ចេញពី(១) ដីគម្របព្រៃឈើឆ្នាំ២០០២ និង(២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន
First Bio-Tech Agricultural (Cambodia) Co;.Ltd និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ
៤២គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



| ចំនុច | Y_Proj | X_Proj | ចំនុច | Y_Proj | X_Proj | ចំនុច | Y_Proj | X_Proj |
|---|---|---|---|---|---|---|---|---|
| 001 | 1223939 | 412375 | 039 | 1222445 | 411179 | 077 | 1222080 | 410915 |
| 002 | 1223658 | 412628 | 040 | 1222431 | 411174 | 078 | 1222131 | 410922 |
| 003 | 1223532 | 412702 | 041 | 1222411 | 411171 | 079 | 1222178 | 410923 |
| 004 | 1223358 | 412787 | 042 | 1222393 | 411186 | 080 | 1222234 | 410925 |
| 005 | 1223359 | 412748 | 043 | 1222364 | 411212 | 081 | 1222286 | 410921 |
| 006 | 1223363 | 412674 | 044 | 1222346 | 411282 | 082 | 1222334 | 410922 |
| 007 | 1223369 | 412670 | 045 | 1222296 | 411275 | 083 | 1222383 | 410926 |
| 008 | 1223495 | 412594 | 046 | 1222246 | 411261 | 084 | 1222436 | 410932 |
| 009 | 1223758 | 412262 | 047 | 1222196 | 411245 | 085 | 1222455 | 410936 |
| 010 | 1223731 | 412144 | 048 | 1222148 | 411229 | 086 | 1222463 | 410940 |
| 011 | 1223693 | 412068 | 049 | 1222104 | 411215 | 087 | 1222479 | 410954 |
| 012 | 1223749 | 412064 | 050 | 1222057 | 411197 | 088 | 1222521 | 410990 |
| 013 | 1223792 | 412029 | 051 | 1222007 | 411179 | 089 | 1222563 | 411026 |
| 014 | 1223805 | 411857 | 052 | 1221986 | 411168 | 090 | 1222614 | 411058 |
| 015 | 1223789 | 411810 | 053 | 1221919 | 411254 | 091 | 1222663 | 411093 |
| 016 | 1223757 | 411810 | 054 | 1221917 | 411255 | 092 | 1222704 | 411123 |
| 017 | 1223708 | 411770 | 055 | 1221859 | 411332 | 093 | 1222745 | 411151 |
| 018 | 1223620 | 411743 | 056 | 1221843 | 411322 | 094 | 1222788 | 411174 |
| 019 | 1223512 | 411727 | 057 | 1221801 | 411290 | 095 | 1222836 | 411198 |
| 020 | 1223366 | 411729 | 058 | 1221754 | 411266 | 096 | 1223279 | 411527 |
| 021 | 1223271 | 411743 | 059 | 1221709 | 411240 | 097 | 1223334 | 411555 |
| 022 | 1223264 | 411744 | 060 | 1221690 | 411145 | 098 | 1223381 | 411580 |
| 023 | 1223312 | 411579 | 061 | 1221690 | 411145 | 099 | 1223482 | 411631 |
| 024 | 1223271 | 411572 | 062 | 1221652 | 411101 | 100 | 1223552 | 411611 |
| 025 | 1223217 | 411543 | 063 | 1221609 | 411070 | 101 | 1223646 | 411606 |
| 026 | 1223218 | 411540 | 064 | 1221557 | 411066 | 102 | 1223742 | 411623 |
| 027 | 1222841 | 411417 | 065 | 1221511 | 411044 | 103 | 1223817 | 411607 |
| 028 | 1222839 | 411413 | 066 | 1221581 | 410816 | 104 | 1223856 | 411647 |
| 029 | 1222783 | 411292 | 067 | 1221586 | 410802 | 105 | 1223904 | 411729 |
| 030 | 1222745 | 411269 | 068 | 1221633 | 410821 | 106 | 1223925 | 411835 |
| 031 | 1222703 | 411250 | 069 | 1221683 | 410838 | 107 | 1223937 | 411982 |
| 032 | 1222666 | 411235 | 070 | 1221732 | 410851 | 108 | 1223928 | 412039 |
| 033 | 1222660 | 411231 | 071 | 1221780 | 410864 | 109 | 1223898 | 412139 |
| 034 | 1222631 | 411216 | 072 | 1221830 | 410880 | 110 | 1223892 | 412212 |
| 035 | 1222575 | 411211 | 073 | 1221884 | 410882 | 111 | 1223890 | 412237 |
| 036 | 1222522 | 411193 | 074 | 1221929 | 410887 | 112 | 1223911 | 412334 |
| 037 | 1222470 | 411179 | 075 | 1221979 | 410898 | | | |
| 038 | 1222461 | 411173 | 076 | 1222029 | 410906 | | | |




## សញ្ញាសម្គាល់

- ភូមិ
- ឃុំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៦៧,៧៩៥២ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ៦២,០៥៨២ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ៥,៦៩៧០ហិកតា
- ផ្លូវទឹក, អូរ, ស្ទឹង
- ផ្លូវ, ភ្នំ

ទិន្នន័យគម្របព្រៃឈើ២០០២
- ព្រៃស្រោង

មាត្រដ្ឋាន 1:20,000

0 155 310 620 930 1,240 Meters

Coodinate System Projection UTM
Zone 48N , Map Datum WGS84